ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសាធារណការ និងដឹកជញ្ជូន**

លេខ: ០០៧ សក.សជណ.ដជគ

# សេចក្តីជូនដំណឹង
## ស្តីពី
## បណ្ណបើកបរយានយន្តដែលអនុញ្ញាតឱ្យប្រើប្រាស់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា

ក្រសួងសាធារណការ និងដឹកជញ្ជូន មានកិត្តិយសសូមជម្រាបជូនដំណឹងដល់សាធារណជនទាំងអស់ មេត្តាជ្រាបថា យោងតាមសេចក្តីជូនដំណឹងលេខ ០០៨ សជណ.សក ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៦ ចំពោះលោក លោកស្រីដែលកាន់បណ្ណបើកបរមានសុពលភាពអចិន្ត្រៃយ៍ ក្រសួងសាធារណការ និងដឹកជញ្ជូន សូមធ្វើការជូនដំណឹងដូចខាងក្រោម៖

- បណ្ណបើកបរយានយន្ត ដែលមានសុពលភាពអចិន្ត្រៃយ៍ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ត្រឹមថ្ងៃទី**៣០ ខែមិថុនា ឆ្នាំ២០២៦** ជាកំហិត។
- បណ្ណបើកបរយានយន្ត ដែលមានសុពលភាពហួតដល់អាយុ ៦០ឆ្នាំគិតពីឆ្នាំកំណើត លោក លោកស្រី អាចបន្តប្រើប្រាស់បណ្ណបើកបរបានរហូតដល់ថ្ងៃអស់សុពលភាពដែលបានកំណត់នៅលើបណ្ណនោះ។

ដោយឡែក ចំពោះសាធារណជនដែលមានបំណងចង់ប្តូរយកបណ្ណបើកបរយានយន្តគំរូថ្មី (ដែលមានសុពលភាព ១០ឆ្នាំ) ក្រសួងសាធារណការ និងដឹកជញ្ជូន នឹងរៀបចំប្តូរជូនទៅតាមនីតិវិធីជាធរមាន។

អាស្រ័យហេតុនេះ សូមសាធារណជនទាំងអស់ មេត្តាជ្រាបជាព័ត៌មាន និងសូមប្រញាប់ប្រសាន់មកធ្វើបច្ចុប្បន្នភាពនិងប្តូរបណ្ណបើកបរយានយន្ត ឱ្យបានទាន់ពេលវេលា មុនថ្ងៃផុតកំណត់ខាងលើ ដើម្បីចៀសវាងការផាកពិន័យតាមច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។

ថ្ងៃព្រហស្បតិ៍ ១១កើត ខែ ចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០២៦

ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ២ ខណ្ឌឫស្សីកែវ ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥) ២៣ ៤២៦ ៦៤០, (៨៥៥) ២៣ ៤២៧ ៨៦២